UNITED NATIONS
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE AUX DROITS DE L'HOMME

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

OHCHR

*សេចក្តីថ្លែងការណ៍របស់លោកស្រី ណាវី ភីឡៃ ឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប*
*ក្នុងឱកាស*

# ទិវាសិទ្ធិមនុស្ស

១០ ធ្នូ ២០០៩

ទស្សនទាននៃការមិនរើសអើងគឺជាស្នូលនៃសិទ្ធិមនុស្ស ។

សំរាប់ហេតុផលនេះ ប្រធានបទផ្លូវការនៃទិវាសិទ្ធិមនុស្សនេះ ត្រូវបានរៀបចំធ្វើរៀងរាល់ឆ្នាំ ដើម្បីរំលឹកខួបនៃការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ១៩៤៨ ។ ហើយសំរាប់ហេតុផលនេះ និងហេតុផលច្រើនទៀត គេគួរតែមានប្រធានបទក្រៅផ្លូវការមួយរៀងរាល់ថ្ងៃ រៀង រាល់ឆ្នាំ សំរាប់មនុស្សគ្រប់រូប ។

សេចក្តីប្រកាសជាសកលនេះ មានទាំងអស់ ៣០ មាត្រា ដែលក្នុងនោះ ម្ភៃប្រាំមួយមាត្រា ផ្តើមដោយពាក្យ "មនុស្សទាំងអស់ ..." ឬ "គ្មានជនណាម្នាក់..." ។ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាព ទាំងអស់ ។ គ្មាននរណាម្នាក់ត្រូវបានគេផាត់ចេញ(មិនរាប់បញ្ចូល) ។ មនុស្សទាំងអស់ កើតមកមានសេរីភាពនិងសមភាព ក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និង សិទ្ធិ ។ ការមិនរើសអើងត្រូវតែឈ្នះ ។

បច្ចុប្បន្ននេះ យើងមានសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើន ដែលបានបញ្ជៀបទាំងស្រុងនូវទស្សនទាននៃការមិនរើសអើង ។ សន្ធិសញ្ញាទាំងនេះ មានជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមារ សិទ្ធិជនពិការ សិទ្ធិជនភៀសខ្លួន និងសិទ្ធិកម្មករទេសន្តរប្រវេសន៍ អនុសញ្ញាទាំងនេះមានគោលដៅបំបាត់ការរើសអើងពូជសាសន៍ និងការរើសអើងប្រឆាំងនឹងស្ត្រីភេទ ព្រមទាំងសន្ធិសញ្ញាទាក់ទងនឹងវិស័យការងារ សុខភាព និងសាសនា ។ បទដ្ឋានគតិយុត្តទាំងនេះ ត្រូវបានបំពេញបន្ថែមដោយសេចក្តីប្រកាសសំខាន់ៗរបស់អង្គការសហប្រជាជាតិ ដែលចែងលំអិតអំពីសិទ្ធិជនភាគតិច និងសិទ្ធិជនជាតិដើមភាគតិច ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ច្បាប់និងបទដ្ឋានអន្តរជាតិទាំងនេះ ត្រូវបានគាំទ្រដោយច្បាប់ជាតិនិងច្បាប់តំបន់ និងស្ថាប័នច្រើនរយពាន់ ។ បច្ចុប្បន្ននេះ មានប្រទេសតិចតួចណាស់ដែលមានវិស័យអប់រំលក្ខណៈសកលពិតប្រាកដ និងមានប្រទេសតិចតួចជាងនេះទៀត ដែលមានប្រព័ន្ធសុខាភិបាលសាធារណៈបែបសកល។ ហេតុផលទាំងអស់នេះ បង្ហាញលក្ខណៈពិសេសមួយអំពីសមត្ថភាពនិងបំណងប្រាថ្នារបស់មនុស្សជាតិ ចង់បានពិភពលោកមួយដែលមនុស្សគ្រប់រូបមានឱកាសស្មើគ្នា និងការប្រព្រឹត្តស្មើភាពគ្នាចំពោះមុខច្បាប់ ហើយមនុស្សរាប់លាននាក់បានទទួលអត្ថប្រយោជន៍នេះជាយថាហេតុ។

មនុស្សគ្រប់រូបត្រូវតែទទួលបានអ្វីដែលគេផ្តល់ឲ្យខ្លួន ។ នៅពេលយើងទទួលយកភាពខុស គ្នា យើងនឹងនាំមកនូវភាពសម្បូណ៌បែប និងភាពស៊ីជម្រៅបន្ថែមទៀតនៅក្នុងសង្គមរបស់យើង ។

ទោះជាដូច្នេះក្តី ក៏ការរើសអើងនៅតែមិនអាចទប់ស្កាត់បាន ។

ស្ត្រីធ្វើការពីរភាគបីនៃម៉ោងធ្វើការពិភពលោក និងផលិតស្បៀងពាក់កណ្តាលនៃស្បៀងអាហារពិភពលោក ប៉ុន្តែពួកគេបានទទួលកម្រៃត្រឹមតែ១០ ភាគរយនៃប្រាក់ចំណូលពិភពលោក និងមានទ្រព្យសម្បត្តិតិចជាងមួយភាគរយនៃទ្រព្យសម្បត្តិពិភពលោកប៉ុណ្ណោះ ។ ទោះបីជាមានភាពល្អប្រសើរច្រើនក្នុងសតវត្សរ៍កន្លងទៅក្តី ក៏ស្ត្រីនិងកុមារីនៅតែត្រូវគេរើសអើងក្នុងកំរិតខ្លះក្នុងសង្គមទាំង អស់ និងក្នុងកំរិតធំក្នុងសង្គមជាច្រើន ។ រៀងរាល់ថ្ងៃ ស្ត្រីច្រើនឥតគណនា ត្រូវគេរំលោភលើរាង កាយ ឬផ្លូវភេទ ហើយជនល្មើសភាគច្រើនបំផុតមិនត្រូវបានផ្តន្ទាទោស ដែលនាំឲ្យការរំលោភបំពាន នៅថ្ងៃខាងមុខមិនអាចធ្វើឲ្យខ្លាចញញើតបានឡើយ ។

ជនភាគតិចនៅក្នុងតំបន់ទាំងអស់នៃពិភពលោក បន្តប្រឈមមុខនឹងការគំរាមកំហែងធ្ងន់ធ្ងរការរើសអើង និងពូជសាសន៍និយម ហើយជារឿយៗត្រូវបានបដិសេធការចូលយ៉ាងពេញទំហឹងក្នុងជីវភាពសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងវប្បធម៌ ដែលមានសំរាប់ជនភាគច្រើនក្នុងប្រទេស ឬសង្គមដែលពួកគេរស់នៅ ។

បញ្ហាស្រដៀងគ្នានេះដែរ ត្រូវប្រឈមមុខដោយជនជាតិដើមភាគតិចប្រមាណជា ៣៧០ លាននាក់ស្មើនឹងប្រាំភាគរយនៃប្រជាជនពិភពលោក គឺស្មើនឹង ១៥ ភាគរយនៃប្រជាជនក្រីក្របំផុត លើពិភពលោក ។ ជារឿយៗពួកគាត់ត្រូវគេដាក់ឲ្យនៅកៀនកោះ សិទ្ធិជាមូលដ្ឋានជាច្រើនត្រូវបាន ដកហូតរាប់ទាំងសិទ្ធិខាងដីធ្លី និងទ្រព្យសម្បត្តិ និងកង្វះការទទួលបានសេវាសំខាន់ៗ ។

ការរើសអើងពូជសាសន៍និងជាតិពន្ធុក៏មានផងដែរ នៅជុំវិញផ្កាយព្រះគ្រោះនេះ ហើយវាជាទម្រង់មួយក្នុងចំណោមទម្រង់ផ្សេងទៀតនៃការរើសអើងដែលគ្រោះថ្នាក់បំផុត ។ ប្រសិនជាបញ្ហានេះមិនត្រូវបានដោះស្រាយ និងទប់ស្កាត់ឲ្យបានសកម្មទេនោះ វាអាចនឹងនាំឲ្យមានភាពស្អប់ខ្ពើមអំពើហឹង្សាដោយងាយ ហើយរិតតែអាក្រក់ជាងនេះទៀតនោះ គឺការអាចនឹងផ្ទុះឡើងនូវជំលោះឧក្រឹដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រឹដ្ឋកម្មប្រល័យពូជសាសន៍ ។

ការរើសអើងពូជសាសន៍ដោយមូលហេតុសាសនា ឬជំនឿ ក៏ជាបញ្ហាអវិជ្ជមានផងដែរ ។ នៅប្រទេសមួយចំនួន សមាជិកក្រុមខ្លះត្រូវគេកំណត់អំពីរបៀបដែលពួកគេអាចប្រតិបត្តិសាសនា ឬ ជំនឿ និងត្រូវបានគេដកហូតសិទ្ធិជាមូលដ្ឋាន ។ ក្នុងករណីហួសហេតុខ្លះ ស្ថានភាពនេះអាចឈាន ដល់ការកើតមានអំពីហឹង្សជាពួកឬនិកាយ ការកាប់សំលាប់ និងជំលោះ ។ គំនិតអគតិអាចនាំឲ្យ អាប់កេរ្តិ៍ឈ្មោះ និងឯកានិយម ។

ជនភៀសខ្លួន និងជនអន្តោប្រវេសន្ត ជាទូទៅត្រូវបានគេរើសអើង រាប់ទាំងនៅបណ្តា ប្រទេសអ្នកមាន ដែលបុរស ស្ត្រី និងកុមារមិនបានប្រព្រឹត្តបទល្មើស ជារឿយៗត្រូវបានគេដាក់ឃុំ ឃាំងរយៈពេលវែង ។ ជារឿយៗពួកគេបានរងការរើសអើងពីសំណាក់ម្ចាស់ដី ឬម្ចាស់ផ្ទះ និយោជក (ថៅកែ) និងអាជ្ញាធររដ្ឋ និងត្រូវបានគេធ្វើឲ្យអាប់កេរ្តិ៍ឈ្មោះ ឬនិយាយបង្អាច់បង្អូចពីសំណាក់ គណបក្សនយោបាយ អង្គការសារព័ត៌មាន និងសាធារណៈជននានា ។

ក្រុមមនុស្សច្រើនទៀត ប្រឈមមុខនឹងការរើសអើងក្នុងកំរិតមួយខ្ពស់ជាង ឬទាបជាង ។ ក្នុងនោះអ្នកដែលងាយរងការរើសអើងមាន ជនពិការ ជនគ្មានរដ្ឋ ពួកបុរសស្រឡាញ់បុរសដូចគ្នា ស្ត្រីស្រលាញ់ស្ត្រីដូចគ្នា សមាជិកនៃត្រកូលឬវណ្ណៈមួយចំនួន និងមនុស្សចាស់ ។ អ្នកខ្លះទៀតអាច មកតែពីខ្លួនជាសមាជិកក្នុងក្រុមផ្សេង ក៏ត្រូវបានគេរើសអើងដោយសារតែភាពផ្សេងគ្នានេះ ។

អ្នកមិនត្រូវបានគេរើសអើងចំពោះខ្លួន ជារឿយៗមិនយល់អំពីការឈឺចាប់ និងការប្រមាថ មើលងាយ ដែលការរើសអើងមានចំពោះអ្នកដទៃជាមនុស្សដូចគ្នាឡើយ ។ ម្យ៉ាងវិញទៀត ជានិច្ច- កាល ពួកគេមិនដឹងអំពីផលអាក្រក់ខ្លាំង ដែលការរើសអើងមានទៅលើសង្គមទាំងមូលឡើយ ។

ការរើសអើងនាំឲ្យមានការមិនទុកចិត្ត ការអន់ចិត្ត អំពើហឹង្សា ឧក្រិដ្ឋកម្ម និងអសន្តិសុខ និង មិនផ្តល់ប្រយោជន៍ខាងសេដ្ឋកិច្ចឡើយ ដោយសារវាកាត់បន្ថយសង្វាក់ផលិតកម្ម ។ ការរើសអើង ទំនងជាមិនផ្តល់គុណប្រយោជន៍ដល់សង្គមទេ ទោះជាតាមបែបណាក៏ដោយ ។ សូម្បីយ៉ាងនោះ យើងនៅតែបន្តធ្វើវា (យើងសឹងតែទាំងអស់គ្នា) ជារឿយៗធ្វើដោយមិនបានគិត ដោយមិនទាំងដឹង ថាយើងកំពុងតែធ្វើអ្វីទៀតផង ។

អាស្រ័យហេតុនេះ ខ្ញុំសូមជំរុញលើកទឹកចិត្តដល់មនុស្សគ្រប់រូបនៅគ្រប់ទិសទី រាប់ទាំង អ្នកនយោបាយ មន្ត្រីនានា អ្នកដឹកនាំពាណិជ្ជកម្ម សង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិ ប្រព័ន្ធផ្សព្វ ផ្សាយព័ត៌មាន មេដឹកនាំសាសនា គ្រូបង្រៀន និស្សិត បុគ្គលម្នាក់ៗ និងបុគ្គលគ្រប់រូប ឲ្យនាំគ្នា អបអរសាទរទិវាសិទ្ធិមនុស្ស ឆ្នាំ២០០៩ ដោយទទួលយកភាពខុសគ្នា និងសំរេចចាត់វិធានការជាក់ ស្តែង និងជានិរន្ត ដើម្បីបំបាត់ការរើសអើង ។

End.